**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការក្រសួងយុត្តិធម៌

លេខ ៩២៣ ព្ររ.៣.១-៩៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ជម្រាបមក**

**លោកព្រះរាជអាជ្ញាអមតុលាការ ខេត្តក្រចេះ**

**សូមជ្រាប។**

**កម្មវត្ថុ:** ស្តីពីករណីភេរវកម្មបោកគ្រាប់បែក បណ្តាលឱ្យមានមនុស្សស្លាប់០៤នាក់និងរងរបួសចំនួន០៩នាក់។

**យោង:** លិខិតលេខ ៤២. អក-៩៧ ចុះថ្ងៃទី១៩-០៥-៩៧ របស់ព្រះរាជអាជ្ញាអមតុលាការ ខេត្តក្រចេះ ។

ខ្ញុំសូមជម្រាបលោកថា ក្រសួងបានទទួលលិខិតដូចមានចែងក្នុងកម្មវត្ថុនិងយោង ខាងលើដែលមានខ្លឹមសារបញ្ជាក់ថា កាលពីថ្ងៃទី១០-០៥-៩៧ នៅក្នុងបរិវេណទីប្រជុំជនផ្សារអូរឬស្សីស្រុកខេត្តក្រចេះ មានអំពើភេរវកម្មបោកគ្រាប់បែកមួយបានកើតឡើងប្រព្រឹត្តដោយជនមិនស្គាល់មុខ បណ្តាលឱ្យមនុស្ស០៤នាក់ ត្រូវស្លាប់និង០៩នាក់ទៀតរងរបួស ។

ខ្ញុំសូមជម្រាបលោកថា រឿងអំពើប៉ះពាល់ដល់សណ្តាប់ធ្នាប់និងសន្តិសុខសាធាណៈជារឿងដែលព្រះរាជអាជ្ញាទទួលខុសត្រូវផ្ទាល់ ។ អង្គភាពនគរបាលយុត្តិធម៌គ្រាន់តែជាកម្លាំងជំនួយដល់អង្គភាពអយ្យការនិងតុលាការក្នុងការស្រាវជ្រាវរកជនល្មើសនិងបង្ក្រាបបទល្មើសក្រោមការដឹកនាំរបស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ ដូចនេះព្រះរាជអាជ្ញាត្រូវចាត់ចែងឱ្យធ្វើការស៊ើបអង្កេតភ្លាមនឹងជាបន្ទាន់ចំពោះឧក្រិដ្ឋកម្មដែលកើតមានឡើង ហើយតាមដានត្រួតពិនិត្យឱ្យបានស្អិតនិងយ៉ាងសកម្មអំពីលទ្ធផលដែលទទួលបាន ដើម្បីផ្លាស់ប្តូរយុទ្ធវិធីអង្កេតស៊ើបសួរបើជាការចាំបាច់ធ្វើយ៉ាងណាស្រាវជ្រាវរកជនល្មើសឱ្យឃើញឆាប់បំផុត ។

រឿងអំពើភេរវកម្មធ្វើឱ្យបាត់បង់ជីវិតនិងរបួសមនុស្សច្រើនយ៉ាងនេះ មិនអាចស្ងាត់ឈឹងឥតមានដំណឹងអ្វីសោះចំនួន ៣ខែមកហើយនោះទេ។

សូមលោកចាត់ការឱ្យបានម៉ឺងម៉ាត់ឡើងក្នុងរឿងនេះ ដោយសហការឱ្យបានស្អិតរមួតជាមួយនគរបាលខេត្តដើម្បីស្រាវជ្រាវរុករកជនល្មើសឱ្យឃើញ ហើយចោទប្រកាន់ជូនទៅតុលាការជំនុំជម្រះផ្តន្ទាទោសតាមច្បាប់ ។

សូមលោករាយការណ៍ជម្រាបមកក្រសួងអំពីចំណាត់ការសំណុំរឿងនេះ តើការអង្កេតស៊ើបសួរបានធ្វើយ៉ាងណាខ្លះហើយ ហើយបានលទ្ធផលយ៉ាងណាខ្លះ ? រីឯវិធានការចាត់ការបន្តត្រូវធ្វើយ៉ាងណាទៀត ?

ធ្វើនៅភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

ចម្លងជូន

-អយ្យការគ្រប់ខេត្ត.ក្រុង

-តុលាការគ្រប់ខេត្ត.ក្រុង

-ដើម្បីជ្រាបនិងអនុវត្ត